# ហាង Blue Pumpkin របស់កម្ពុជាប្រកាស់លក់ Franchise ហើយ

February 16, 2017




ហាង Blue Pumpkin ដែលជាយីហោខ្មែរមានដើមកំណើតពីខេត្តសៀមរាប ដែលបានបង្កើតឡើងជាង១០ឆ្នាំផ្លាយហើយ ។ សព្វថ្ងៃ ហាងអាហារបែបអឺរ៉ុបមួយនេះ បានពង្រីកខ្លួន ចំនួន ១៥ហាងហើយនៅនៅសៀមរាបនិងភ្នំពេញ។ អ្នកតំណាងប្រធានក្រុមហ៊ុន លោកស្រី Anne Sarin Courcoux បានប្រាប់ពាណិជ្ជកម្មកម្ពុជាថា ឥឡូវនេះក្រុមហ៊ុនកំពុងចាំអាណ្មណ៍ស្វែងរកអ្នកទិញសិទ្ធិ (Franchise) បើកហាង Blue Pumpkin បន្ត។

លោកស្រីដែលជាកូនស្រីរបស់ស្ថាបនិក ក្រុមហ៊ុន Meas Development Holdings បានបញ្ជាក់ថា សព្វថ្ងៃហាង Blue Pumpkin ដែលកំពុងដំណើរការបែប Franchise និងដំណើរការល្អជាងបំផុតគឺ Blue Pumpkin នៅប្រលានយន្តហោះភ្នំពេញ។ លោកស្រីបានបន្តថា នៅមានទីតាំងល្អជាច្រើនទៀត ដែលលោកស្រីចង់លក់សិទ្ធិ Franchise ទៅឲ្យអ្នកដែលចង់បើកហាងមួយនេះ។

សម្រាប់អ្នកដែលចាប់អារម្មណ៍នឹងទិញ Franchise ហាង Blue Pumpkin លោកអ្នកនឹងត្រូវបង់ ថ្លៃសិទ្ធិបើកអាជីវកម្មបន្តនៅដើមគ្រា ហើយនិងបង់ថ្លៃប្រចាំខែ ប្រមាណជា 3-5% លើចំនួនលក់ បានប្រចាំខែផងដែរ។ ខាងក្រុមហ៊ុននឹងផ្តល់ជូននូវប្រព័ន្ធគ្រប់គ្រង និងការណែនាំគ្រប់បែបយ៉ាងដើម្បីជួយសម្រួលដល់អ្នកក្នុងការចាប់ផ្តើមហាង Blue Pumpkinដោយជោគជ័យបាន។ សម្រាប់អ្នកចាប់អារម្មណ៍ សូមទំនាក់ទំនងទៅកាន់លេខ 092 850 854៕

អត្ថបទដោយ៖ សំ កុសល

Sam.businesscambodia.com